**Declassified to Public**
**12 June 2020**

លេខ៖ D216/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 24 / 10 / 2016
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០១៦**

ភាសា ៖ **អង់គ្លេស & ខ្មែរ [អង់គ្លេស ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

## ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិ D216

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**

មុំ លុច
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**

សូ មូស្សេនី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ុន
ទី ស្រីនណា
វ៉ែន ពៅ

Linda BEHNKE
Laure DESFORGES
NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

01339323



## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥។

២. នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរអនុលោមតាមវិធានផ្ទៃក្នុង ៥៥(១០) ដោយស្នើសុំ ស.ច.ស ស្តាប់ចម្លើយ Ben Kiernan និង Rochelle Braaf ព្រមទាំង បំពេញកិច្ចស៊ើបសួរថែមទៀតដើម្បីកំណត់អំពីមូលហេតុនៃការស្លាប់របស់សាក្សីសក្តានុពលឈ្មោះ ង៉ោល(" សំណើ")[1]។

៣. នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ ខ្ញុំបានដាក់ យឹម ទិត្យ ឱ្យស្ថិតក្រោមការពិនិត្យពីបទចោទផ្សេងៗ ដូចជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមានអាពាហ៍ពិពាហ៍ដោយបង្ខំ ជាអំពើអមនុស្សធម៌ផ្សេងទៀត និងអំពើប្រល័យពូជសាសន៍នៅទីតាំងឧក្រិដ្ឋកម្មផ្សេងៗនៅទូទាំងភូមិភាគពាយ័ព្យ និងតំបន់ ១៣ ភូមិភាគនិរតី សម័យកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំបានដាក់ យឹម ទិត្យ ឱ្យស្ថិតក្រោមការពិនិត្យ ដោយសារអតីតតួនាទីរបស់គាត់ជាលេខាស្រុកគិរីវង់ ជាសមាជិកគណៈតំបន់ ១៣ នៅភូមិភាគនិរតី ជាលេខាតំបន់ ១ តំបន់ ៣ តំបន់ ៤ និងជាអនុលេខាភូមិភាគពាយ័ព្យ[2]។

## II. សារណា

៤. នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ ("ដីកាសន្និដ្ឋានទី ៣") ស.ព.អ ចោទថា ជនឈ្មោះ"ង៉ោល" ជាប្រធានឃុំរាមអណ្តើក បានទទួលបញ្ជាពី យឹម ទិត្យ ដើម្បីសម្លាប់មនុស្សមួយចំនួន[3]។ នៅក្នុងសំណើ ស.ព.អ ស្នើថា ដើម្បីទទួលបានភស្តុតាងល្អបំផុតតាម

---

[1] សំណុំរឿង00៤ ឯកសារ D216 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៤។

[2] សំណុំរឿង00៤ ឯកសារ D281 *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ ទំព័រ ៤-២២។

[3] សំណុំរឿង00៤ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ កថាខណ្ឌ ៩៨(គ)។

ដែលអាចទទួលបានអំពីចម្លើយរបស់ ង៉ោល ទាក់ទងនឹងការប្រព្រឹត្តិរបស់ យឹម ទិត្យ ស.ច.ស គួរ៖

ក. បំពេញកិច្ចស៊ើបសួរបែបនេះថែមទៀតតាមដែលអាចចាំបាច់ដើម្បី បញ្ជាក់ពីការស្លាប់របស់ ង៉ោល ព្រមទាំង

ខ. ស្តាប់ចម្លើយ និងយកចម្លើយដែលបានស្បថពី Ben Kiernan ដែលបានសម្ភាស ង៉ោល នៅខែ សីហា ឆ្នាំ ១៩៨០ គឺចម្លើយអំពីកាលៈទេសៈ បញ្ជីឈ្មោះអ្នកមានវត្តមាន និងខ្លឹមសារនៃ៖

i. កិច្ចសម្ភាសន៍ខែសីហា ឆ្នាំ ១៩៨០ របស់គាត់ជាមួយ ង៉ោល និងសំណៅប្រតិចារឹក ខ្សែអាត់សំឡេង ឬវីដេអូ រូបថត ឬកំណត់ហេតុពាក់ព័ន្ធ ដើម្បីដាក់ចូលក្នុងសំណុំរឿង។

ii. ព័ត៌មានដែលគាត់អាចមានអំពី ង៉ោល គ្រួសារគាត់ ឬអ្នកធ្លាប់ធ្វើការជាមួយគាត់ ដែលជួយបញ្ជាក់ការពិតថាតើ ង៉ោល ពិតជាស្លាប់ហើយឬនៅ។

៥. ស.ព.អ ស្នើថា ស.ច.ស គួរទទួលបានសំណៅប្រតិចារឹក ខ្សែអាត់សំឡេង ឬវីដេអូ រូបថត ឬកំណត់ហេតុកិច្ចសម្ភាសន៍ដែលបានដកស្រង់នៅក្នុងឯកសារបោះពុម្ពផ្សាយរបស់ Ben Kiernan ចំណងជើង *របប ប៉ុល ពត៖ ជាតិពិន្ទុ អំណាច និងអំពើប្រល័យពូជសាសន៍ក្នុងសម័យខ្មែរក្រហម ឆ្នាំ ១៩៧៥-ឆ្នាំ ១៩៧៩* ដោយរាប់បញ្ចូល ប៉ុន្តែមិនកំណត់នៅត្រឹមអ្វីដែលបានលើកឡើងនៅទំព័រ ២៣០ ដល់ ២៤៦ នៃឯកសារនេះជាភាសាអង់គ្លេសស្តីពីរចនាសម្ព័ន្ធអំណាច និងការបោសសម្អាតនៅភូមិភាគពាយ័ព្យ ដើម្បីដាក់ឯកសារទាំងនេះ ចូលក្នុងសំណុំរឿង[4]។ ស.ព.អ បញ្ជាក់ថា សំណើនេះពាក់ព័ន្ធនឹងការចោទប្រកាន់នានានៅក្នុងដីកាសន្និដ្ឋានទី ៣ ទាក់ទងនឹងការដឹងឮ និងការទទួលខុសត្រូវរបស់ យឹម ទិត្យ ចំពោះការចាប់ខ្លួន និងការសម្លាប់មនុស្សនៅភូមិភាគពាយ័ព្យ បន្ទាប់ពីកម្មាភិបាលភូមិភាគនិរតីទៅដល់[5]។

[4]សំណើ កថាខណ្ឌ ២-៣។

[5]សំណើ កថាខណ្ឌ ២ ដោយដកស្រង់កថាខណ្ឌ ៩៨(ខ)នៃដីកាសន្និដ្ឋានទី ៣។

៦. ស.ព.អ ស្នើថា ដើម្បីពន្លឿនកិច្ចស៊ើបសួរអំពីការចោទប្រកាន់នានាដែលបានលើកឡើងនៅកថាខណ្ឌ ៤ ដល់ ១០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬយេនឌ័រ("ដីកាសន្និដ្ឋានបន្ថែម")[6] និងដើម្បីប្រើប្រាស់ឱ្យបានប្រសើរបំផុតនូវធនធាន និងពេលវេលាស៊ើបសួរនោះ ស.ច.ស គួរស្តាប់ចម្លើយសាក្សី ឬស្វែងរកមតិយោបល់ជំនាញពី Rochelle Braaf ជាអ្នកស៊ើបអង្កេតនាំមុខនៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដែលបានបោះពុម្ពឯកសារស្រាវជ្រាវចុះដល់ទីកន្លែងចំណងជើង *"អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម"* ("របាយការណ៍របស់ក្រុមអ្នកច្បាប់ការពារសិទ្ធកម្ពុជា")[7] ក្នុងគោលបំណងដើម្បីវាយតម្លៃ៖

ក. លក្ខណៈ វិសាលភាព វិធីសាស្រ្ត ប្រភពឯកសារ និងក្របខណ្ឌពេលវេលានៃការស្រាវជ្រាវចុះដល់ទីកន្លែងរបស់គាត់អំពីអំពើហិង្សាផ្លូវភេទ និងយេនឌ័រដែលបានប្រព្រឹត្តនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ជាពិសេសអំពើហិង្សាផ្លូវភេទ និងយេនឌ័រមកលើខ្មែរក្រោម វៀតណាម និង/ឬចាម ដើម្បីបញ្ជាក់ពីភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាននៃការរករឿងរបស់គាត់ សម្រាប់បញ្ជាក់ពីការពិតនៃអង្គហេតុដែលបានចោទនៅក្នុងដីកាសន្និដ្ឋានបន្ថែម។

ខ. លក្ខណៈ ប្រភេទ វិសាលភាព និងទីកន្លែងនៃការចោទប្រកាន់អំពីអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ និងយេនឌ័រ ដែលជាផ្នែកមួយនៃការស្រាវជ្រាវនេះ។

គ. លទ្ធភាពដែល Rochelle Braaf ទំនងជាមានបំណងផ្តល់ជូន ស.ច.ស នូវសេចក្តីសង្ខេប ប្រតិចារឹក ឬខ្សែអាត់ដោយមានការកោសលុប ឬដោយអនាមិកអំពីកិច្ចសម្ភាសន៍របស់គាត់ជាមួយនឹងអ្នកចូលរួមការស្រាវជ្រាវនេះ។

---

[6]សំណើ កថាខណ្ឌ ១ និង ៤ ដោយដកស្រង់សំណុំរឿង ០០៤ ឯកសារ D191 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬយេនឌ័រ* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ៤-១០។

[7]សំណុំរឿង០០៤ ឯកសារ D219/115.1 *អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម* ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤។

ឃ. លទ្ធភាពដែល Rochelle Braaf ទំនងជាមានបំណងទាក់ទងអ្នកដែលបានសម្ភាសជាមួយនឹងគាត់ ហើយសក្ខីកម្មរបស់អ្នកទាំងនោះអាចជួយបញ្ជាក់ពីការពិតអំពីការចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានបន្ថែម ដើម្បីទទួលបានការការយល់ព្រមពីពួកគាត់ដោយពួកគាត់ទទួលបានព័ត៌មាន ក្នុងគោលបំណងដើម្បីបង្ហាញឈ្មោះ និងព័ត៌មានទំនាក់ទំនងពួកគាត់ជូនទៅស.ច.ស[8]។

## III. ពិភាក្សា

៧. អង្គបុរេជំនុំជម្រះ("អ.ប.ជ")ធ្លាប់បានបញ្ជាក់ថា ភាគីដែលស្នើសុំបំពេញកិច្ចស៊ើបសួរ"*ត្រូវបំពេញលក្ខខណ្ឌត្រួតលើគ្នាចំនួនពីរ [...] ពោលគឺ សំណើសុំត្រូវតែ៖*

*(១) កំណត់បង្ហាញអំពីសកម្មភាពដែលត្រូវធ្វើ ឬដីកាដែលត្រូវធ្វើ ដោយមានការបញ្ជាក់ឱ្យបានច្បាស់លាស់("លក្ខខណ្ឌនៃភាពច្បាស់លាស់") និង*

*(២) បង្ហាញឱ្យបានពិស្តារអំពីមូលហេតុអ្វីបានជាសំណើបំពេញកិច្ចស៊ើបសួរដែលបានស្នើសុំ ឬកិច្ចដែលកើតចេញមកពីដីកាដែលធ្វើឡើង [...]មានការ"ពាក់ព័ន្ធទៅនឹងការបញ្ជាក់នូវការពិត"ជាបឋម(លក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋម)*
"[9]។

៨. លក្ខខណ្ឌនៃភាពច្បាស់លាស់ តម្រូវឱ្យភាគីដែលស្នើ ជាប់កាតព្វកិច្ច"*ត្រូវមានភាពច្បាស់លាស់គ្រប់គ្រាន់ដើម្បីធ្វើការបង្ហាញឱ្យបានច្បាស់លាស់ដល់សហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធនឹងកិច្ចការអ្វីដែលសហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរ*"[10]។ ហេតុនេះ ខ្ញុំមិនជាប់លក្ខខណ្ឌត្រូវអនុញ្ញាតតាមសំណើមានលក្ខណៈជាទូទៅ ឬប៉ាន់ស្មាន ដែលស្នើសុំស្វែងរកភស្តុតាង

---

[8]សំណើ កថាខណ្ឌ ៥។

[9]សំណុំរឿង ០០២ ឯកសារ D365/2/17 *សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង* ("សាលដីកាស្តីពីការពិចារណាឡើងវិញ") ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ៤៧។

[10]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨។

ដោះបន្ទុកឡើយ[11]។ ប៉ុន្តែ ភាគីដែលស្នើ ត្រូវតែចង្អុលបង្ហាញឱ្យបានច្បាស់លាស់អំពីវត្តមាននៃភស្តុតាងដែលត្រូវស្វែងរក[12]។ ឧទាហរណ៍ អ.ប.ជ បានសម្រេចថា សំណើសុំដែលមិនបានលើកឡើងច្បាស់លាស់អំពីចំនួនឯកសារ ឬអំពីទីតាំងច្បាស់លាស់ដែលប្រមូលបានឯកសារនោះ ឬទីតាំងទុកដាក់ឯកសារនោះ គឺខកខានមិនបានបំពេញលក្ខខណ្ឌនៃភាពច្បាស់លាស់ឡើយ[13]។

៩. លក្ខខណ្ឌនៃភាពពាក់ព័ន្ធ មានលក្ខខណ្ឌរងចំនួនពីរ។ ទី ១ សំណើ ត្រូវ"*មានការពាក់ព័ន្ធជាមួយនឹងវិសាលភាពនៃការស៊ើបសួរ អនុលោមតាមការកំណត់ និងព្រំដែនដែលបានកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម*"[14]។ ទី ២ សំណើ "*ត្រូវរៀបរាប់លម្អិតអំពីមូលហេតុអ្វីបានជាកិច្ចស្នើដែលជាកម្មវត្ថុនៃដីកាសម្រេចនឹងនាំឱ្យរកឃើញនូវការពិត*"[15]។ លក្ខខណ្ឌនេះតម្រូវថា ភាគីដែលស្នើសុំ ត្រូវបញ្ជាក់ពីចំណងទាក់ទងជាបឋមរវាងកិច្ចស៊ើបសួរដែលបានស្នើសុំ ជាមួយនឹងបញ្ហាដែលស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ[16]។ ក្នុងករណីដែលសំណើពាក់ព័ន្ធនឹងភស្តុតាងដោះបន្ទុក ភាគីដែលស្នើសុំ

[11]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៤៨ និង ៥១។

[12]សំណុំរឿង00២ ឯកសារ D100/9/2 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើលើកទីពីររបស់ ខៀវ ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៣១។ សំណុំរឿង00២ ឯកសារD164/4/13*សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកទៅក្នុងឃ្លាំងផ្ទុកឯកសាររួមរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើលើកទីពីររបស់ ខៀវ ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៣៩។ សំណុំរឿង00២ ឯកសារ D353/2/3 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ"ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១០* ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៤៧។ សំណុំរឿង00២ ឯកសារ D273/3/5 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស លើសំណើលើកទី ១៨ របស់ ខៀវ ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១០។ សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨ និង ៧៣។

[13]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨។

[14]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៩។

[15]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៥០។

[16]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៥០-៥១។

01339328



ត្រូវបង្ហាញពីមូលហេតុជាបឋមដែលថា ការបំពេញកិច្ចស៊ើបសួរអាចនាំឱ្យមានភស្តុតាងដោះបន្ទុក[17]។

១០. ខ្ញុំជឿថា សំណើ បំពេញតាមលក្ខខណ្ឌតម្រូវនៃភាពច្បាស់លាស់ និងភាពពាក់ព័ន្ធ ដែល អ.ប.ជ បានបញ្ជាក់។ ខាងក្រោមនេះគឺជាការបង្ហាញពីកិច្ចស៊ើបសួរដែលការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") បានបំពេញជាការឆ្លើយតបទៅនឹងសំណើ។

## ក. ស៊ើបអង្កេតអំពីការស្លាប់របស់ ង៉ោល

១១. នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានធ្វើដំណើរទៅស្រុកមោងឫស្សី ហើយបានរកឃើញកូនស្រីរបស់ ង៉ោល ឈ្មោះ សួត រានី។ សួត រានី បានប្រាប់អ្នកស៊ើបអង្កេតថា ង៉ោល បានស្លាប់ដោយសារជំងឺគ្រុនចាញ់នៅឆ្នាំ ១៩៨៦ ហើយគាត់នៅជាមួយ ង៉ោល នៅពេលនោះ[18]។ គាត់ក៏បានបង្ហាញអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស នូវធាតុរបស់ ង៉ោល ដែលបានរក្សាទុកនៅក្នុងចេតិយតូចមួយនៅក្នុងបរិវេណដីគាត់[19]។ សួត រានី បានបញ្ជាក់ថា មិនមានសំបុត្រមរណភាព ឬក៏លិខិតផ្សេងទៀតដែលបញ្ជាក់ពីការស្លាប់របស់គាត់ឡើយ ដោយសារមានការប្រយុទ្ធគ្នាជាមួយខ្មែរក្រហមនៅក្នុងតំបន់នោះនៅពេលនោះ[20]។ មិនមានមូលហេតុត្រូវសង្ស័យអំពីភាពត្រឹមត្រូវនៃចម្លើយរបស់ សួត រ៉ានី អំពីការស្លាប់របស់ ង៉ោល ឡើយ។

១២. អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានសាកសួរមនុស្សពីរនាក់ផ្សេងទៀតដែលបានអះអាងថាធ្លាប់បានស្គាល់ ង៉ោល ហើយអ្នកទាំងនោះបានបញ្ជាក់ថា ង៉ោល បានស្លាប់នៅពោធិ៍សាត់

---

[17]សំណុំរឿង០០២ ឯកសារ D353/2/3 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ"ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១០* ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៤៧។

[18]សំណុំរឿង០០៤ ឯកសារ D219/48 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ២[អង់គ្លេស]។ សូមមើលផងដែរ សំណុំរឿង០០៤ ឯកសារ D118/309 ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៤។

[19]សំណុំរឿង០០៤ ឯកសារ D219/48 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ២[អង់គ្លេស]។

[20]ដូចជើងទំព័រខាងលើ។

01339329



នៅឆ្នាំ ១៩៩០[21]។ សាក្សីម្នាក់ទៀតដែល ក.ស.ច.ស បានសម្ភាស បានបញ្ជាក់ថា ង៉ោល បាន ស្លាប់នៅខេត្តបាត់ដំបង[22]។

១៣. ដោយពិនិត្យមើលព័ត៌មានពីកូនស្រីរបស់ ង៉ោល និងការបញ្ជាក់ពីមនុស្សផ្សេងទៀតទាំងនោះ ខ្ញុំជឿថា មិនចាំបាច់ត្រូវស៊ើបសួរថែមទៀតដើម្បីបញ្ជាក់ពីការស្លាប់របស់ ង៉ោល ឡើយ ហើយសំណើ ត្រង់ចំណុចនេះ ដូចបានបង្ហាញនៅកថាខណ្ឌ ៤.ក និង ៤.ខ ខាងលើ ត្រូវបាន ឆ្លើយតបរួចហើយ។

**ខ. ស្តាប់ចម្លើយ Ben Kiernan**

១៤. នៅថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ ខ្ញុំបានសរសេរលិខិតទៅ Ben Kiernan ដោយស្នើសុំ (ក) ពេលទំនេរដែលគាត់អាចផ្តល់ការស្តាប់ចម្លើយអំពីកាលៈទេសៈ និងខ្លឹមសារនៃកិច្ចសម្ភាសន៍ របស់គាត់ជាមួយនឹង ង៉ោល និង (ខ) ការបញ្ជាក់ពីគាត់ថាតើ គាត់មានបំណងផ្តល់ជូន ស.ច.ស នូវប្រតិចារឹក ខ្សែអាត់សំឡេង ឬវីដេអូ រូបថត ឬកំណត់ហេតុដែលគាត់អាចមាន ទាក់ទងនឹងកិច្ចសម្ភាសន៍របស់គាត់ជាមួយនឹង ង៉ោល ឬអ្នកផ្សេងទៀតដែលបានផ្តល់ព័ត៌មាន អំពីឈ្មោះ "ទិត្យ" និងរចនាសម្ព័ន្ធអំណាចនៅភូមិភាគពាយ័ព្យ ដោយរាប់បញ្ចូល ប៉ុន្តែមិន កំណត់នៅត្រឹមអ្នកផ្តល់កិច្ចសម្ភាសន៍ដែលបានដកស្រង់នៅទំព័រ ២៣០ ដល់ ២៤៦ នៃ សៀវភៅរបស់គាត់ ចំណងជើង *របប ប៉ុល ពត៖ ជាតិពិន្ទុ អំណាច និងអំពើប្រល័យពូជ សាសន៍ក្នុងសម័យខ្មែរក្រហម ឆ្នាំ ១៩៧៥-ឆ្នាំ ១៩៧៩*[23]។

១៥. នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៦ Ben Kiernan បានឆ្លើយតបដោយបញ្ជាក់ថា គាត់លែង មានពេលដើម្បីផ្តល់ការស្តាប់ចម្លើយជាមួយនឹង អ.វ.ត.ក ទៀតហើយ។ ប៉ុន្តែ Ben Kiernan ពិតជាបានផ្តល់ជូននូវសំណៅបកប្រែជាភាសាអង់គ្លេសសរសេរដោយដៃគាត់អំពីកិច្ច សម្ភាសន៍របស់គាត់នៅឆ្នាំ ១៩៨០ ជាមួយនឹង ង៉ោល និង លីវ សារុន(Lieu Sarun) ជា

---

[21]សំណុំរឿង004 ឯកសារ D219/48 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី២២ ខែតុលា ឆ្នាំ ២០១៤ ទំព័រ ១-២[អង់គ្លេស]។

[22]សំណុំរឿង004 ឯកសារ D118/46 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពួច សេង* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ ERN00905860 ឆ.២៤។

[23]សូមមើលឧបសម្ព័ន្ធ ក ភ្ជាប់ជាមួយនឹងដីកាសម្រេចនេះ៖ "*លិខិតពីចៅក្រម Michael Bohlander ផ្ញើជូន Ben Kiernan អំពី"ពេលទំនេរដើម្បីផ្តល់ការស្តាប់ចម្លើយជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រាប់កិច្ចស៊ើបសួរសំណុំរឿង 004 ដែលកំពុងបន្តដំណើរការ និងសំណើសុំឯកសារ*" ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦។

សាក្សីម្នាក់ ដែលនិយាយពីឈ្មោះ ង៉ោល ជាច្រើនដងនៅក្នុងកិច្ចសម្ភាសន៍របស់គាត់[24]។ ក្រោយមក សំណៅបកប្រែជាភាសាអង់គ្លេសសរសេរដោយដៃនេះបានដាក់ចូលក្នុងសំណុំរឿង[25]។ ក.ស.ច.ស បានទទួលប្រតិចារឹកជាភាសាអង់គ្លេស និងភាសាខ្មែរនៃកំណត់ហេតុទាំងពីរដែលសរសេរដោយដៃ ហើយប្រតិចារឹកទាំងនេះនឹងដាក់ចូលក្នុងសំណុំរឿង។ ហេតុនេះ សំណើរបស់ ស.ព.អ ដូចបានបង្ហាញនៅកថាខណ្ឌ ៤.ខ.i ខាងលើ ត្រូវបានឆ្លើយតបហើយ។

១៦. ដោយពិនិត្យមើលព័ត៌មានដែល ក.ស.ច.ស ទទួលបានទាក់ទងនឹងការស្លាប់របស់ ង៉ោល[26] និងដោយពិចារណាលើការផ្តល់កំណត់ហេតុរបស់ Ben Kiernan អំពីកិច្ចសម្ភាសន៍របស់គាត់ជាមួយនឹង ង៉ោល ខ្ញុំយល់ឃើញថា មិនចាំបាច់បង្ខំឱ្យ Ben Kiernan មកបង្ហាញខ្លួនចូលរួមការស្តាប់ចម្លើយ ដូចដែល ស.ព.អ បានស្នើឡើយ។

## គ. សំណើសុំកំណត់ហេតុនៃកិច្ចសម្ភាសន៍សាក្សីរបស់ Ben Kiernan

១៧. ចំពោះសំណើដែលបានបង្ហាញនៅកថាខណ្ឌ ៥ ខាងលើ Ben Kiernan បានបញ្ជាក់នៅក្នុងចម្លើយតបរបស់គាត់ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៦ ថា គាត់បានផ្តល់ជូន ក.ស.ច.ស រួចហើយនូវខ្សែអាត់សំឡេងនៃកិច្ចសម្ភាសន៍របស់គាត់ជាមួយឈ្មោះ "សាន" ហើយភស្តុតាងពីឈ្មោះ សាន ត្រូវបានលើកយោងនៅទំព័រ ២៣០ ដល់ ២៣៩ និងទំព័រ ២៣៩ ដល់ ២៤១ នៃសៀវភៅរបស់គាត់ ចំណងជើង *របប ប៉ុល ពត៖ ជាតិពន្ធុ អំណាច និងអំពើប្រល័យពូជសាសន៍ក្នុងសម័យខ្មែរក្រហម ឆ្នាំ ១៩៧៥-ឆ្នាំ ១៩៧៩*។ ខ្សែអាត់សំឡេងនៃកិច្ចសម្ភាសន៍នេះមាននៅក្នុងសំណុំរឿង 00២[27]។

---

[24]សូមមើលឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយនឹងដីកាសម្រេចនេះ៖ អ៊ីមែលពី *Ben Kiernan ផ្ញើជូន Wendy Lobwein អំពី"ការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស)"* ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៦។

[25]សំណុំរឿង00៤ ឯកសារ D219/726 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦។

[26]ដូចជើងទំព័រខាងលើ កថាខណ្ឌ ១១-១២។

[27]សំណុំរឿង00២ ឯកសារ D269/9/1.5R សាន *(សុន សំ-Sun Sam) ត្រូវបាន* Ben Kiernan *សម្ភាស ប៉ារីស ២៩-0៥-១៩៨0* កាសែតទី ១ *#89A* ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៨0។ សំណុំរឿង ២ ឯកសារ D269/9/1.6R សាន *(សុន សំ-Sun Sam) ត្រូវបាន* Ben Kiernan *សម្ភាស ប៉ារីស ២៩-0៥-១៩៨0* កាសែតទី ២ *#89B* ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៨0។ សំណុំរឿង ២ ឯកសារ D269/9/1.7R សាន *(សុន សំ-Sun Sam) ត្រូវបាន* Ben Kiernan *សម្ភាស ប៉ារីស ២៩-0៥-១៩៨0* កាសែតទី ៣ *#89C* ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៨0។

១៨. នៅក្នុងខ្សែអាត់សំឡេង សាន មិនបានផ្តល់ភស្តុតាងណាដែលពាក់ព័ន្ធនឹងការចោទប្រកាន់ប្រឆាំង យឹម ទិត្យ ទេ ជាពិសេសការចោទប្រកាន់ដែល ស.ព.អ បានដកស្រង់នៅក្នុងសំណើ[28]។ ប៉ុន្តែ គាត់ផ្តល់ភស្តុតាងអំពីរចនាសម្ព័ន្ធភូមិភាគពាយ័ព្យមុនពេល និងក្រោយពេលដែលកម្មាភិបាលភូមិភាគនិរតីមកដល់នៅឆ្នាំ ១៩៧៧ ជាភស្តុតាងពាក់ព័ន្ធនឹងការបោសសម្អាតភូមិភាគពាយ័ព្យនៅពាក់កណ្តាលឆ្នាំ ១៩៧៧[29]។ សាន បញ្ជាក់ថា ក្នុងនាមជាអ្នកស្ថិតិធ្វើការឱ្យគណៈតំបន់ ៥ គាត់បានដឹងអំពីផែនការរបស់អង្គការដែលត្រូវផ្លាស់ទីលំនៅប្រជាជនថ្មីចំនួន ២៣០ ០០០ នាក់ពីភ្នំពេញ មកតំបន់ ៥ នៅភូមិភាគពាយ័ព្យនៅឆ្នាំ ១៩៧៦។ ភស្តុតាងនេះពាក់ព័ន្ធនឹងការចោទប្រកាន់នៅក្នុងសំណុំរឿង ០០៤ អំពីគោលនយោបាយរបស់រដ្ឋក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង ឱ្យទៅសហករណ៍កសិកម្ម រោងចក្រ និងការដ្ឋាន[30]។ ខ្សែអាត់សំឡេងនេះ រួមជាមួយនឹងប្រតិចារឹក នឹងដាក់ចូលក្នុងសំណុំរឿង ០០៤។

១៩. សៀវភៅរបស់ Ben Kiernan មាននៅក្នុងសំណុំរឿង ០០៤ រួចហើយ[31]។ សៀវនេះមានភស្តុតាងពីសាក្សីដែលបង្ហាញឱ្យឃើញថាពាក់ព័ន្ធនឹងការចោទប្រកាន់កាន់តែទូទៅអំពីរចនាសម្ព័ន្ធថ្នាក់ដឹកនាំនៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ស្ថានភាពរស់នៅ និងស្ថានភាពការងារនៅភូមិភាគទាំងនោះ។ ហេតុនេះ តាមរយៈចម្លើយតបរបស់ Ben Kiernan ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៦ បង្ហាញឱ្យឃើញថា គាត់មិនមានកំណត់ហេតុបន្ថែមទៀតដើម្បីផ្តល់ជូនឡើយ ក្រៅពីកំណត់ហេតុដែលបានបង្ហាញនៅក្នុងអ៊ីមែលរបស់គាត់ ប៉ុន្តែ ខ្ញុំបានសរសេរលិខិតទៅ Ben Kiernan នៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ដើម្បីឱ្យអស់ចិត្ត ដោយធ្វើការស្នើសុំខ្សែអាត់សំឡេង កំណត់ហេតុ និងកំណត់ហេតុផ្សេងទៀតនៃកិច្ចសម្ភាសន៍ដែលគាត់បានធ្វើឡើងជាមួយសាក្សីនានាដែលភស្តុតាងពីសាក្សីទាំងនោះ ខ្ញុំចាត់ទុកថាអាចពាក់ព័ន្ធនឹងការ

---

[28]សំណើ កថាខណ្ឌ ១-២ ដោយដកស្រង់ដីកាសន្និដ្ឋានទី ៣ កថាខណ្ឌ ៩៨(ខ) និង ៩៨(គ)។

[29]សូមមើល ដីកាសន្និដ្ឋានទី ៣ កថាខណ្ឌ ៤,៨, ១០,១៧ និង ៥៤-៥៩។

[30]សូមមើល ដីកាសន្និដ្ឋានទី ៣ កថាខណ្ឌ ៧។

[31]សំណុំរឿង០០៤ ឯកសារ D6.1.1105 សៀវភៅរបស់ Ben Kiernan ចំណងជើង *របប ប៉ុល ពត៖ ជាតិពន្ធុ អំណាច និងអំពើប្រល័យពូជសាសន៍ក្នុងសម័យខ្មែរក្រហម ឆ្នាំ ១៩៧៥-ឆ្នាំ ១៩៧៩* ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៧៨ ដាក់នៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១១។

ចោទប្រកាន់ទាំងនោះ[32]។ រហូតមកដល់ថ្ងៃនេះ Ben Kiernan មិនទាន់ឆ្លើយតបទៅនឹងលិខិតរបស់ខ្ញុំទេ។

២០. ប៉ុន្តែ ផ្អែកតាមអ្វីដែលអាចទទួលបានពីសៀវភៅរបស់ Ben Kiernan គឺថា ជាបឋម មិនមានការបង្ហាញថា កំណត់ហេតុដែលខ្ញុំបានស្នើពី Ben Kiernan អាចមានភាពពាក់ព័ន្ធ និងតម្លៃភស្តុតាង ដែលជាមូលហេតុត្រូវចំណាយធនធាន និងពេលវេលាថែមទៀតដើម្បីបន្តការស៊ើបសួរនេះឡើយ។ ខ្ញុំក៏បានពិចារណាផងដែរអំពីការឆ្លើយតបមិនបានគ្រប់គ្រាន់ពី Ben Kiernan និងការបង្ហាញនៅក្នុងអ៊ីមែលរបស់គាត់ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៦ ដែលថា គាត់ប្រហែលជាមិនមានកំណត់ហេតុថែមទៀតឡើយ។

២១. គ្មានកិច្ចស៊ើបសួរបន្ថែមទៀតនឹងត្រូវធ្វើឡើងដើម្បីទទួលបានកំណត់ហេតុនៃកិច្ចសម្ភាសន៍សាក្សីដែល Ben Kiernan បានពឹងផ្អែកនៅក្នុងសៀវភៅរបស់គាត់ឡើយ។

### ឃ. ស្តាប់ចម្លើយ Rochelle Braff

២២. នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤ អ្នកស៊ើបអង្កេតម្នាក់របស់ ក.ស.ច.ស បានជួបប្រជុំជាមួយនឹង Rochelle Braaff និង ដួង សាវន មកពីក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា។ ក្នុងឱកាសនោះ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានបញ្ជាក់ថា ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា មានកំណត់ហេតុនៃកិច្ចសម្ភាសន៍ដែលជាមូលដ្ឋាននៃរបាយការណ៍របស់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ហើយកំណត់ហេតុទាំងនោះ អាចប្រគល់ជូន ក.ស.ច.ស ដើម្បីត្រួតពិនិត្យក្នុងទម្រង់មិនបង្ហាញអត្តសញ្ញាណ ដើម្បីកុំឱ្យរំលោភបំពានការធានារក្សាការសម្ងាត់របស់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ជាមួយអ្នកផ្តល់កិច្ចសម្ភាសន៍[33]។

២៣. នៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានស្តាប់ចម្លើយ Rochelle Braaff ហើយបានរៀបចំកំណត់ហេតុស្តាប់ចម្លើយនេះ(កំណត់ហេតុស្តាប់ចម្លើយ

---

[32] *សូមមើល* ឧបសម្ព័ន្ធ គ ភ្ជាប់ជាមួយនឹងដីកាសម្រេចនេះ៖ *លិខិតពីចៅក្រម Michael Bohlander ផ្ញើជូន Ben Kiernan អំពី "សំណើបន្ទាប់សុំឯកសារទាក់ទងនឹងកិច្ចស៊ើបសួរសំណុំរឿង ០០៤"* ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦។

[33] សំណុំរឿង០០៤ ឯកសារ D219/115 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

Braaff)[34]។ Braaff បានផ្ដល់ភស្តុតាងអំពីតួនាទីរបស់គាត់នៅក្នុងការរៀបចំរបាយការណ៍របស់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា វិធីសាស្ត្រ ប្រភពថវិកា និងរយៈពេលនៃការស្រាវជ្រាវចុះដល់ទីកន្លែងនេះ ព្រមទាំងឆន្ទៈរបស់គាត់ក្នុងការផ្ដល់ជូន ក.ស.ច.ស នូវប្រតិចារឹកកោសលុប និង/ឬមិនបង្ហាញអត្តសញ្ញាណនៃកិច្ចសម្ភាន៍ពាក់ព័ន្ធ ដើម្បីធ្វើការត្រួតពិនិត្យ។

២៤. ដូចបានបង្ហាញនៅក្នុងបញ្ជីសំណួរភ្ជាប់ជាមួយនឹងកំណត់ហេតុស្ដាប់ចម្លើយ Braaff គឺថា អ្នកផ្ដល់សម្ភាសន៍នៅក្នុងការស្រាវជ្រាវចុះដល់ទីកន្លែងនេះត្រូវបានសួរសំណួរអំពីបញ្ហាផ្សេងៗ ដូចជា ជាតិពិន្ទុ ឋានៈ និងទីលំនៅរបស់ពួកគាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព័ត៌មានលម្អិតអំពីការរៀបការ ការរួមសង្វាសក្រោយរៀបការ ភស្តុតាងអំពីការរំលោភផ្លូវភេទ ទីតាំង និងពេលវេលាដែលអំពើបែបនេះបានកើតឡើង ចារី ផលប៉ះពាល់ផ្លូវចិត្ត និងផ្លូវកាយមកលើអ្នកផ្ដល់សម្ភាសន៍ដែលបានឆ្លងកាត់អំពីហិង្សា[35]។

២៥. ហេតុនេះ ខ្ញុំជឿថា ព័ត៌មានដែលបានផ្ដល់នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ Braaff និងរបាយការណ៍របស់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដែលបង្ហាញលម្អិតផងដែរអំពីវិធីសាស្ត្រនៃការស្រាវជ្រាវចុះដល់ទីកន្លែងនេះ និងប្រភពថវិកា[36] គឺជាព័ត៌មានដែលបានឆ្លើយតបសំណើរបស់ ស.ព.អ ដូចបានបង្ហាញខាងលើនៅកថាខណ្ឌ ៦.ក និង ៦.ខ។

២៦. នៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ អ្នកវិភាគម្នាក់របស់ ក.ស.ច.ស បានចុះទៅការិយាល័យរបស់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ហើយបានត្រួតពិនិត្យមើលបញ្ជីសំណួរសម្ភាសន៍ទាំង ១០៥ ដែលជាមូលដ្ឋាននៃរបាយការណ៍របស់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដោយបានរកឃើញថា បញ្ជីសំណួរសម្ភាសន៍ចំនួន ៦៥ អាចពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ តាមទីតាំងភូមិសាស្ត្ររបស់អ្នកផ្ដល់សម្ភាសន៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[37]។ សំណៅនៃបញ្ជីសំណួរ

[34]សំណុំរឿង០០៤ ឯកសារ D219/91 *កំណត់ហេតុនៃការស្ដាប់ចម្លើយ Rochelle Braaf* ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

[35]សំណុំរឿង០០៤ ឯកសារ D219/91.1 *ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ការស្រាវជ្រាវអំពីអំពើហិង្សាផ្លូវភេទចំពោះក្រុមជនជាតិភាគតិចឆ្នាំ ២០១៣* ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៣។

[36]របាយការណ៍របស់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ទំព័រ vi, ២៤-៣១។

[37]សំណុំរឿង០០៤ ឯកសារD219/115 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ សំណុំរឿង០០៤ ឯកសារD219/540 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៥ ទំព័រ ១-៣។

សម្ភាសន៍ទាំង ៦៥ នេះ ដោយដកចេញនូវព័ត៌មានបង្ហាញអត្តសញ្ញាណរបស់អ្នកផ្តល់សម្ភាសន៍ បានដាក់ចូលក្នុងសំណុំរឿងរួចហើយ[38]។

២៧. Rochelle Braaff បានជូនដំណឹង ក.ស.ច.ស ថា ខ្សែអាត់សំឡេងនៃកិច្ចសម្ភាសន៍ទាំងនោះត្រូវបានបំផ្លាញចោលហើយដោយសារមូលហេតុរក្សាការសម្ងាត់[39]។ Rochelle Braaff បានផ្តល់ជូន ក.ស.ច.ស នូវប្រតិចារឹកខ្សែអាត់សំឡេងនៃកិច្ចសម្ភាសន៍ទាំង ១០៥ ដោយគ្មានឈ្មោះអ្នកផ្តល់កិច្ចសម្ភាសន៍ ក្នុងលក្ខខណ្ឌថា ប្រតិចារឹកទាំងនេះត្រូវចាត់ថ្នាក់ជាឯកសារ "សម្ងាត់" ហើយមានតែ ក.ស.ច.ស អង្គជំនុំជម្រះសាលាដំបូង និងភាគីទេ ដែលអាចចូលពិនិត្យមើលប្រតិចារឹកទាំងនោះបាន[40]។

២៨. ក.ស.ច.ស បានត្រួតពិនិត្យមើលប្រតិចារឹកនៃបញ្ជីសំណួរសម្ភាសន៍ទាំង ៦៥ ដែលអាចពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ ហើយបានរកឃើញថា បញ្ជីសំណួរសម្ភាសន៍ចំនួន ៤៣ ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ។ ប្រតិចារឹកនៃបញ្ជីសំណួរសម្ភាសន៍ទាំង ៤៣ នេះ បានដាក់ចូលក្នុងសំណុំរឿងរួចហើយ[41]។

២៩. ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានរក្សាទុកព័ត៌មានលម្អិតសម្រាប់ធ្វើការទាក់ទង និងបង្ហាញអត្តសញ្ញាណអ្នកផ្តល់សម្ភាសន៍ចាប់តាំងពីពេលដែល Rochelle Braaff ចាកចេញពីប្រទេសកម្ពុជា កាលពីខែ វិច្ឆិកា ឆ្នាំ ២០១៤[42]។ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានបញ្ជាក់ថា ខ្លួនយល់ព្រមអនុញ្ញាតឱ្យអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ចូលពិនិត្យមើលព័ត៌មាននោះ[43]។ ស.ព.អ មិនបានស្នើសុំឱ្យធ្វើបែបនេះឡើយនៅក្នុងសំណើរបស់ខ្លួន ប៉ុន្តែ ក.ស.ច.ស

---

[38] *សូមមើល*ឧបសម្ព័ន្ធនានា ភ្ជាប់ជាមួយនឹងសំណុំរឿង០០៤ ឯកសារ D219/115 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

[39] សំណុំរឿង០០៤ ឯកសារ D219/126 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤ ទំព័រ ២[អង់គ្លេស]។ សំណុំរឿង០០៤ ឯកសារ D219/540 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៥ ទំព័រ ៣។ សំណុំរឿង ០០៤ ឯកសារD 219/738 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ៣[អង់គ្លេស]។

[40] សំណុំរឿង០០៤ ឯកសារ D219/738 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ៣[អង់គ្លេស]។

[41] *សូមមើល* ឧបសម្ព័ន្ធ D219/738.1 ដល់ D219/738.43 ភ្ជាប់ជាមួយនឹងសំណុំរឿង០០៤ ឯកសារD219/738 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ៣[អង់គ្លេស]។

[42] កំណត់ហេតុស្តាប់ចម្លើយ Braaff ឆ. ១២ និង ឆ.១៣។

[43] សំណុំរឿង០០៤ ឯកសារ D219/540 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៥ ទំព័រ ១-៣។

បច្ចុប្បន្ននេះកំពុងត្រួតពិនិត្យមើលប្រតិចារឹកទាំងនេះដើម្បីកំណត់ថាតើ អ្នកផ្តល់សម្ភាសន៍ជាមួយក្រុមអ្នកច្បាប់ការពារសិទ្ធិម្ភុជា គួរ ឬមិនគួរត្រូវទាក់ទងដើម្បីធ្វើការស្តាប់ចម្លើយនៅក្នុងកិច្ចស៊ើបសួរសំណុំរឿង ០០៤។

៣០. ដោយពិនិត្យមើលកិច្ចស៊ើបសួរដែលបានអនុវត្តរហូតមកសព្វថ្ងៃនេះ ខ្ញុំយល់ឃើញថា សំណើរបស់ ស.ព.អ ដូចបានបង្ហាញនៅកថាខណ្ឌ ៦.គ និង ៦.ឃ ត្រូវបានឆ្លើយតបហើយ។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

៣១. **ជូនដំណឹង** ស.ព.អ ថា ខ្ញុំយល់ឃើញថា បញ្ហាដែលបានស្នើនៅក្នុងសំណើ ត្រូវបានស៊ើបអង្កេតគ្រប់គ្រាន់រួចហើយ ហេតុនេះ សំណើត្រូវបានឆ្លើយតបហើយ។

៣២. **បង្គាប់** ក្រឡាបញ្ជី ត្រូវដាក់ចូលក្នុងសំណុំរឿង ០០៤ នូវឯកសារដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ឃ ភ្ជាប់ជាមួយនឹងដីកាសម្រេចនេះ។

ភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**